ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ **២១ "ញ"**
-ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ១១៦៨
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧
-ស៊ើបសួរលេខ ១២៤៧
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧
-ជំនុំជម្រះលេខ ១៣៨៨
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ,នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ សាលសវនាការទី៣ ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៦៨ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ប្រជាការពារសាលាសង្កាត់ដង្កោ ទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សៀង "ស" ម្តាយឈ្មោះ [redacted] វ៉ែន "ស" ប្រពន្ធឈ្មោះ [redacted] រី "រ" មានកូន ០៤នាក់ ជានីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

២-ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទប្រុស អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ យោធាអគ្គបញ្ជាការបញ្ជូនសារ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃនៅភូមិគងនយ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យាន "រ" ម្តាយឈ្មោះ [redacted] សេង "ស" ប្រពន្ធឈ្មោះ [redacted] សុខទៀង មានកូន ០២នាក់ ជានីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់



Scanned with CamScanner

ភូមិបាល និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

## ដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] **ស៊ុនប៉ា** ភេទប្រុស អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ២៩CE₀ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយមានលោក [redacted] ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០០៥ ឈ្មោះ [redacted] បុប្ផា ឈ្មោះ [redacted] ឆេង ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] តុក បានសហការគ្នាទិញដីមួយកន្លែងពីឈ្មោះ [redacted] សំអឿន ក្នុងទំហំ ១៧.៥០០ម៉ែត្រការ៉េ ស្ថិតនៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយឈ្មោះ គង់ បុប្ផា ឈរឈ្មោះជាអ្នកទិញដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣១៥/០៥ ប.ជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ។ ក្រោយមកនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ ឈ្មោះ [redacted] ស៊ុនប៉ា បានទិញដីនេះបន្តដោយយោងតាមលិខិតផ្ទេរសិទ្ធិលេខ ៤៨៦/០៥ ប.ជ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ ។ បន្ទាប់ពីទិញដីរួចឈ្មោះ [redacted] ស៊ុនប៉ា បានឱ្យឈ្មោះ [redacted] វ៉ាន់ ជួយមើលថែដីខាងលើនោះជំនួស លុះដល់អំឡុងឆ្នាំ២០១៥ ស្រាប់តែឈ្មោះ [redacted] យឹម មកបោះបង្គោលព័ទ្ធយកដីរបស់ឈ្មោះ [redacted] ស៊ុនប៉ា ដោយសម្អាងទៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ មានឈ្មោះ [redacted] សំអឿន ផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] យឹម ដែលមិនចុះថ្ងៃ.ខែ.ឆ្នាំ និងមិនមានការបញ្ជាក់ដឹងឮពីអាជ្ញាធរមូលដ្ឋានភូមិសង្កាត់ឡើយ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០៧៥ អ.យ.ម ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ២១៩៨ អ.យ.ម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៥០ "ឃ១" ដ.ដ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានឆ្លើយថា ៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយមូលហេតុថា ដីទំនាស់ដែលដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា ប្តឹងខ្លួនថា លួចលក់ គឺមានទីតាំងខុសគ្នា ដីរបស់ឈ្មោះ [redacted] ស៊ុនប៉ា មានទីតាំងនៅភូមិជើងឯក ចំណែកដីរបស់ខ្លួនមានទីតាំងនៅភូមិខ្វា ដោយសារដីដែលជាកម្មសិទ្ធិរបស់ខ្លួន ដែលរដ្ឋចែកឱ្យខ្លួន មានទីតាំងភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ដីរបស់ខ្លួន ដែលរដ្ឋបានចែកដីឱ្យខ្លួន មានទំហំ ២៨អា ជាប្រភេទដីស្រែប្រាំង ខ្លួនមានសាក្សី និងអាជ្ញាធរដឹងឮ ។ នៅឆ្នាំ២០០៥ ខ្លួនបាន ព្រមព្រៀងលក់ដីនេះ ទៅឱ្យឈ្មោះ [redacted] វ៉ាន់ ក្នុងតម្លៃ ៦$/ម៉ែត្រការ៉េ ដោយឈ្មោះ [redacted] វ៉ាន់ បានកក់ប្រាក់ ឱ្យខ្លួនចំនួន ៥.១០០ (ប្រាំពាន់មួយរយ)ដុល្លារអាមេរិក ដោយចាប់តាំងពីពេលកក់ប្រាក់ មកឈ្មោះ [redacted] វ៉ាន់ មិនដែលបានជួបខ្លួនឡើយ ហើយខ្លួនក៏នៅកាន់កាប់ដីនោះដដែល លុះដល់ឆ្នាំ២០០៨ ខ្លួនក៏បានជួលដីនេះឱ្យ ទៅឈ្មោះ [redacted] អ៊ុច និងប្រពន្ធ ដើម្បីដាំត្រកួន រហូតដល់ឆ្នាំ២០១២ ស្រាប់តែឈ្មោះ [redacted] យឹម

បានមកបោះបង្គោលលើដីរបស់ខ្លួន ខ្លួនក៏បានទៅសួរនាំ ថាហេតុអ្វីមកបោះបង្គោលលើដីខ្លួនទៅវិញ ស្រាប់តែឈ្មោះ [redacted] យឹម ប្រាប់ថា គាត់បានទិញដីនេះពីឈ្មោះ [redacted] វ៉ាន់ ទើបខ្លួនប្រាប់ទៅវិញថា ឈ្មោះ [redacted] វ៉ាន់ ទិញដីនេះពីខ្លួន មិនទាន់បានឱ្យលុយគ្រប់ទេ លុះក្រោយមកពួកខ្លួនទាំងបីនាក់ ក៏បានព្រមព្រៀងគ្នាលក់ដីនេះឱ្យទៅឈ្មោះ តាំង យឹម ដោយឈ្មោះ [redacted] យឹម ចេញសងជំនួសឈ្មោះ [redacted] វ៉ាន់ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ នៅចំពោះមុខមេភូមិខ្វា លោក [redacted] ប៊ុន ចុះហត្ថលេខានៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ។ បន្ទាប់មកឈ្មោះ [redacted] យឹម ជាម្ចាស់ថ្មី នៅបន្តជួលដីនេះ ឱ្យទៅឈ្មោះ [redacted] អ៊ុច និងប្រពន្ធ ដើម្បីដាំត្រកួនដដែល ។ កន្លងមកខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ស៊ុនប៉ា ទេ ។ ស្រាប់តែនៅក្នុងអំឡុង ឆ្នាំ២០១៦ ស្រាប់តែខ្លួនឮគេប្រាប់ថា មានឈ្មោះ [redacted] ស៊ុនប៉ា មកអះអាងថា ជាដីរបស់គាត់ ហើយមានការតវ៉ាជាមួយប្រជាជន ព្រោះគាត់អះអាងថាជាដីដែលគាត់ទិញពីប្រជាជន ដែលតាមពិតប្រជាជនម្ចាស់ដីទាំងនោះ មិនបានលក់ឱ្យគាត់នោះទេ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] បុប្ផា ឈ្មោះ [redacted] ឆេង ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] តុក និងឈ្មោះ [redacted] ស៊ុនប៉ា ទេ ។ ខ្លួនក៏ពុំមានដីនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ហើយក៏មិនដែលបានធ្វើលិខិតទិញលក់ដីជាមួយនឹងឈ្មោះ [redacted] បុប្ផា នេះទេ ។ ចំពោះលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលមានចុះហត្ថលេខា ដោយមេភូមិជើងឯក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៥ និងមានការបញ្ជាក់ដោយសង្កាត់ជើងឯកលេខ ៣១៥/១៥ ប.ជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ដែលមានខ្លឹមសារថា ខ្លួនបានផ្ទេរសិទ្ធ ដីនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ទំហំ ១៧៥០០ម៉ែត្រការ៉េ ឱ្យឈ្មោះ [redacted] បុប្ផា នោះ ខ្លួនមិនបានផ្តិតម្រាមដៃទេ ។ ឈ្មោះ [redacted] សារី ឈ្មោះ [redacted] វ៉ាសនា ខ្លួនមិនស្គាល់ទេ ។ ខ្លួនបានផ្ទេរសិទ្ធិឱ្យទៅតែឈ្មោះ [redacted] យឹម ចំនួន ២៨អា តាមលិខិតនៅចំពោះមុខមេភូមិ ឆ្នាំ២០១២ ទំហំ ១០.០០០ម៉ែត្រការ៉េ ពីព្រោះថាដីផ្សេងទៀតជាដីរបស់ប្រជាពលរដ្ឋ ចំនួន ០៥គ្រួសារផ្សេងទៀត ដែលមានផ្ទៃដី ទំហំ សរុប ១០.០០០ម៉ែត្រការ៉េ ។

-ជនជាប់ចោទឈ្មោះ [redacted] **យឹម** បានឆ្លើយថា ៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនពុំបានសមគំនិតក្នុងអំពើលួចលក់អចលនវត្ថុ ដែលមិនមែនជារបស់ខ្លួន និងប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ។ ដីដែលដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងខ្លួនថា លួចលក់នោះ ដោយសារដីនេះ គឺជារបស់ខ្លួន ដំបូងឡើយខ្លួនបានទិញដីពីឈ្មោះ [redacted] វ៉ាន់ ជាច្រើនកន្លែង ក្រោយមកខ្លួនទទួលដំណឹងថា ឈ្មោះ [redacted] វ៉ាន់ យកដីខ្លួនលក់អស់ ហើយខ្លួនប្រាប់ថា នឹងប្តឹងឈ្មោះ [redacted] វ៉ាន់ ថាបើមិនដោះស្រាយឱ្យខ្លួន ទើបឈ្មោះ [redacted] វ៉ាន់ បានមកសម្រុះសម្រួលជាមួយខ្លួន ហើយក៏បានព្រមព្រៀងគ្នា ដោយគាត់បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីមួយកន្លែង ទំហំ ១,៥ហិកតា នៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ ប្អូនរិន ខាងត្បូងទល់ [redacted] ផល្លី ខាងកើតទល់ [redacted] សុជាតិ ខាងលិចទល់ ប្អូនស្នា មានលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ដោយមិនមានចុះហត្ថលេខាពីអាជ្ញាធរទេ ។ ពេលធ្វើលិខិតនេះហើយ ខ្លួនបានឱ្យឈ្មោះ [redacted] វ៉ាន់ ជូនខ្លួនទៅបោះបង្គោល តែឈ្មោះ [redacted] វ៉ាន់ បានគេចវេសរហូត ។ ខ្លួនក៏បានទៅទីតាំងដីតាមការចង្អុលប្រាប់ពីឈ្មោះ [redacted] វ៉ាន់ ហើយបានទំនាក់ទំនងជាមួយអ្នកដែលកំពុងជួលដីដាំត្រកួន ។ ខ្លួនបានប្រាប់អ្នកដាំត្រកួនថា ដីនេះខ្លួនទិញពីឈ្មោះ [redacted] វ៉ាន់ ហើយបានផ្ទេរសិទ្ធិរួចហើយ ។ អ្នកដាំត្រកួនថា លិខិតឱ្យ

ត្រឹមត្រូវទៅ ព្រោះឮថា [redacted] វ៉ាន់ មិនទាន់ឱ្យលុយម្ចាស់ដីដើមគ្រប់ទេ ។ ខ្លួនក៏បានចុះកិច្ចសន្យាជួលដីនេះឱ្យទៅអ្នកដាំត្រកួន ឈ្មោះ [redacted] អ៊ុច និងប្រពន្ធឈ្មោះ [redacted] ថាវី នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ន ។ ដោយសារលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ មិនមានការចុះហត្ថលេខាពីអាជ្ញាធរ ខ្លួនមិនទុកចិត្ត ទើបខ្លួនសម្រេចប្ដឹងមកអយ្យការសាលាដំបូងរាជធានីភ្នំពេញតែម្ដង ។ ពេលមានការប្ដឹងឈ្មោះ អ៊ុក វ៉ាន់ បានព្រមធ្វើកិច្ចព្រមព្រៀងជាមួយខ្លួន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដោយមានមេធាវីដឹងឮ ។ ពេលមានកិច្ចព្រមព្រៀង ខ្លួន និងឈ្មោះ [redacted] វ៉ាន់ ដោយមានសមត្ថកិច្ចប៉េអឹម មេភូមិ មេឃុំ ប្រជាពលរដ្ឋ ចូលរួមបានចុះទៅ បោះបង្គោល ស្រាប់តែមានឈ្មោះ [redacted] សំអឿន មកតវ៉ា ថាដីនេះជាដីរបស់គាត់ ហើយថាដីនេះឈ្មោះ [redacted] វ៉ាន់ បានទិញគាត់ ([redacted] សំអឿន) ដោយបានកក់ប្រាក់បានតែ ៥.១០០ (ប្រាំពាន់មួយរយ)ដុល្លារអាមេរិក តែប៉ុណ្ណោះ កក់រយៈពេល ៣ឆ្នាំមកហើយ នាពេលនោះ ។ ខ្លួនបានព្រមព្រៀងបង់ប្រាក់បង្គ្រប់ឱ្យឈ្មោះ [redacted] សិន ព្រោះគាត់យោគយល់ថា ខ្លួនជាជនរងគ្រោះដែរ ដោយមានការនិយាយអង្វរពីប្រជាពលរដ្ឋ មេភូមិ ជាពិសេស អ្នកជួលដីដាំត្រកួនតែម្ដង ។ ខ្លួន និងឈ្មោះ [redacted] សំអឿន បានធ្វើលិខិតផ្ទេរសិទ្ធិជាមួយគ្នា ដោយពុំបានចុះកាលបរិច្ឆេទ និងហត្ថលេខាពីអាជ្ញាធរទេ ។ លិខិតផ្ទេរសិទ្ធិដី/ផ្ទះ ដែលពុំមានចុះកាលបរិច្ឆេទ ហើយមានស្នាមមេដៃម្ចាស់ដីដើម និងសាក្សីឈ្មោះ [redacted] រី (ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សំអឿន) កើតចេញឡើងដោយមានមូលហេតុថា ពួកខ្លួនផ្ដិតមេដៃមិននៅចំពោះមុខមេភូមិ ទើបមេភូមិមិនព្រមចុះហត្ថលេខាលើលិខិតនេះ ហើយមេភូមិក៏បានទុកចោលលើតុគាត់ ។ បន្ទាប់មកមេភូមិបានឱ្យពួកខ្លួនធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ សារជាថ្មីដោយបានផ្ដិតមេដៃចំពោះមុខគាត់ ទើបគាត់ព្រមចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះថ្មីនេះ ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២។ ខ្លួនបានបង់ប្រាក់បង្គ្រប់ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ពីរឆ្នាំក្រោយបន្ទាប់ពីការកាន់កាប់រយៈពេល ២ឆ្នាំ មិនដែលមានបញ្ហា ។ នៅអំឡុងពេលដែលខ្លួនចុះទៅវាស់វែងដាំបង្គោល និងមានការព្រមព្រៀងជាមួយឈ្មោះ [redacted] សំអឿន មានប្រជាពលរដ្ឋចូលរួមដែរ ក្នុងនោះមានសាច់ញាតិរបស់ឈ្មោះ [redacted] សំអឿន និងប្រជាពលរដ្ឋមានចំនួនប្រហែល ២០ ទៅ ៣០នាក់ ។ ខ្លួនមិនចាំអ្នកណាខ្លះនោះទេ ។ នាពេលដែលខ្លួនចុះបោះបង្គោលក្នុងឆ្នាំ២០១២ នៅលើដីនោះគ្មានបង្គោលរបងទេ។ ក្រោយមកខ្លួនបានបោះបង្គោលចាក់បេតុង ដើម្បីកំណត់ព្រំដីខ្ញុំ ។ ពេលបោះបង្គោលវាស់ជាក់ស្ដែង បានតែ ១ហិកតា ប៉ុណ្ណោះ មិនមែន ១,៥ហិកតា ដូចដែលឈ្មោះ [redacted] វ៉ាន់ ផ្ទេរមកឱ្យខ្លួនទេ។ ដីនោះដើមឡើយជាដីធ្វើស្រែប្រាំង តែក្រោយមកគេបិតទ្វារទឹក ទើបធ្វើឱ្យលិចទឹក ។ ព្រោះតែដីនោះជាដីលិចទឹកទើបខ្លួនពុំដឹងពីទំហំពិតប្រាកដ ចំពោះព្រំ គឺខ្លួនដឹងតាមការអះអាងរបស់អ្នកដែលដាំត្រកួនលើដីនោះតែប៉ុណ្ណោះ ។ ដីនោះ ពិតជានៅភូមិខ្វា សង្កាត់ដង្កោ ប្រាកដមែន ដោយមានលិខិតបញ្ជាក់របស់មេភូមិ [redacted] ប៊ុន និងចៅសង្កាត់ដង្កោ [redacted] សាមឿន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ។ នៅមុនពេលចេញលិខិតបញ្ជាក់នេះ មេភូមិខ្វា គាត់បានចុះទៅមើលទីតាំងដីជាក់ស្ដែង ហេតុនេះ គាត់ច្បាស់លាស់ណាស់ថា ដីនោះពិតជាស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ប្រាកដមែន ។ ចំពោះលិខិតប្រគល់ប្រាក់ថ្លៃដីផ្ដាច់ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្លួនបានធ្វើឡើងដោយមានសាក្សី និងមេភូមិដឹងឮ ។ លិខិតប្រគល់ប្រាក់នេះ គឺមានសងខាងតែដើមបណ្ដឹងបានថតចម្លងយកមកដាក់ជូនតុលាការតែម្ខាងប៉ុណ្ណោះ ។ កន្លងមកខ្លួនមិនដែលមានទំនាស់ជាមួយ

ឈ្មោះ [redacted] ស៊ុនប៉ា ទេ ។ ចាប់តាំងពីខ្លួនជួលឱ្យអ្នកដាំ ត្រកួនមកខ្លួនមិនដែលចូលទៅទីតាំងដីនោះទេ ។ ដីនោះ ឈ្មោះ [redacted] ស៊ុនប៉ា អះអាងថា ជាដីរបស់គាត់ទាំងមូលតែម្តង តែតាមពិតដីរបស់ឈ្មោះ [redacted] ស៊ុនប៉ា ស្ថិតនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ចំណែកដីខ្លួនស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយមានលិខិតទទួលស្គាល់ពី មេភូមិ និងចៅសង្កាត់ត្រឹមត្រូវ ។ នៅអំឡុងឆ្នាំ២០១៥ ខ្លួនមិនបានបោះបង្គោលនៅលើដីទំនាស់នោះទេ ។ ដីនោះខ្លួនបានបោះបង្គោលតាំងពីឆ្នាំ២០១២ មកម្ល៉េះ ។ អំឡុងឆ្នាំ ២០១២ រហូតដល់ឆ្នាំ២០១៥ ឈ្មោះ [redacted] អ៊ិច ជាអ្នកនៅលើដីនោះ រហូតមក ។ កន្លងមកខ្លួនមិនដែលស្គាល់ ឈ្មោះ [redacted] ស៊ុនប៉ា ទេ លុះនៅឆ្នាំ២០១៥ ទើបខ្លួនបានដឹងថាឈ្មោះ ឡៅ ស៊ុនប៉ា បានប្តឹងខ្លួន ។

-សាក្សីឈ្មោះ [redacted] **សាអឿន** បានឆ្លើយថា ៖ ខ្លួនបានស្បថរួចហើយ ។ ខ្លួនពុំមានជាប់សាច់ញាតិអ្វីជាមួយនឹង ឈ្មោះ [redacted] ស៊ុនប៉ា ,ឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឡើយ ខ្លួនធ្លាប់ធ្វើជាចៅសង្កាត់ដង្កោ នៅអំឡុងខែកញ្ញា ឆ្នាំ១៩៨១ និងបាន ឈប់ពីមុខងារនេះ នៅឆ្នាំ២០១៧ នៅពេលមានការប្រកាសសុពលភាព ចៅសង្កាត់ថ្មី ។ ដីទំនាស់ដែលមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ហើយមានចុះហត្ថលេខា របស់មេភូមិ [redacted] ប៊ុន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដែលមានឈ្មោះ [redacted] សំអឿន ផ្ទេរសិទ្ធិដី ដែលមាន ទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ មានទំហំ ១០.០០០ម៉ែត្រការ៉េ ឱ្យទៅឈ្មោះ [redacted] យឹម គឺពិតជាដីដែលមានទីតាំងនៅ ភូមិខ្វា ប្រាកដមែន មិនមែនស្ថិតនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌ ដង្កោ ដូចការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា នោះទេ ។ ខ្លួនសុំបញ្ជាក់ពីប្រវត្តិដីនេះថា ដើមឡើយឈ្មោះ [redacted] យឹម មានការប្តឹងផ្តល់ជាមួយឈ្មោះ [redacted] វ៉ាន់ ក្រោយមកមានការព្រមព្រៀងគ្នា ដោយឈ្មោះ [redacted] វ៉ាន់ យល់ព្រមសងដីឱ្យឈ្មោះ [redacted] យឹម ដែលមានទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ហើយឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] យឹម បានមកសាលាសង្កាត់ដង្កោស្នើសុំធ្វើលិខិតផ្ទេរ សិទ្ធិដី ភូមិខ្វា ឱ្យទៅឈ្មោះ [redacted] យឹម ខ្លួនក៏បានចាត់មន្ត្រីសង្កាត់មួយរូប គឺលោក [redacted] ទឹម ជាសមាជិកក្រុម ប្រឹក្សាសង្កាត់ទទួលបន្ទុកទំនាស់ដីធ្លី និងមេភូមិខ្វា លោក [redacted] ប៊ុន ដើម្បីចុះទៅពិនិត្យទីតាំង និងធ្វើការកំណត់ ព្រំ ដើម្បីធ្វើលិខិតផ្ទេរសិទ្ធ ។ ក្រោយមកឈ្មោះ [redacted] សំអឿន ចេញមកអះអាងថាដីនោះ ជាដីរបស់គាត់ដែល បានលក់ឱ្យឈ្មោះ [redacted] វ៉ាន់ តែឈ្មោះ [redacted] វ៉ាន់ បានព្រមព្រៀងគ្នាដោយឈ្មោះ [redacted] យឹម ព្រមព្រៀងចេញ លុយជំនួសឈ្មោះ [redacted] វ៉ាន់ បង្គ្រប់ថ្លៃដីឱ្យទៅឈ្មោះ [redacted] សំអឿន ។ ហើយឈ្មោះ [redacted] សំអឿន បានព្រម ព្រៀងផ្តិតមេដៃទទួលប្រាក់ និងផ្ទេរសិទ្ធិដីទំនាស់ដែលមានទីតាំងនៅភូមិខ្វា ឱ្យទៅឈ្មោះ [redacted] យឹម តែម្តង ។ សូមបញ្ជាក់ថា ដីនេះ ឈ្មោះ [redacted] សំអឿន ជាម្ចាស់ដីដែលបានកាន់កាប់បន្តពីដូនតា មក និងធ្វើស្រែប្រាំងនៅ ពេលរដូវទឹកស្រកជាប្រចាំ ហើយគាត់ក៏ជាអ្នកស្រុកភូមិនៅទីនោះ ។ នៅពេលដែលឈ្មោះ [redacted] វ៉ាន់ ចុះទៅ ចង្អុលដី គឺដីនោះពិតជាមាន ទីតាំងនៅភូមិខ្វាប្រាកដមែន ។ មុនពេលរឿងទំនាស់នេះកើតឡើង ខ្លួនមិនដែល ស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា នេះទេ ។ ចំពោះរូបថតទីតាំងដី ដែលតុលាការបានបង្ហាញខ្លួន នេះ ខ្លួនមិនអាចចំណាំបានទេ ព្រោះខ្លួនមិនបានចុះទៅទីតាំងផ្ទាល់ទេ ស្នើសុំតុលាការចុះពិនិត្យភូមិសាស្ត្រជាក់ ស្តែងចុះ ។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted] **ប៉ុន** បានឆ្លើយថា ៖ ខ្លួនបានស្បថរួចហើយ ។ ខ្លួនពុំមានជាប់សាច់ញាតិអ្វីជាមួយនឹងឈ្មោះ [redacted] ស៊ុនប៉ា ,ឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឡើយ ។ ខ្លួនជាអនុភូមិខ្វា តាំងពីឆ្នាំ១៩៩០ ហើយបានឡើងជាមេភូមិនៅឆ្នាំ២០០៦ ។ ដីទំនាស់ដែលមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ហើយមានចុះហត្ថលេខារបស់ខ្លួន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដែលមានឈ្មោះ [redacted] សំអឿន ផ្ទេរសិទ្ធិដី ដែលមានទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ មានទំហំ ១០.០០០ម៉ែត្រការ៉េ ឱ្យទៅឈ្មោះ [redacted] យឹម គឺពិតជាដីដែលមានទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានទំហំ ១០.០០០ម៉ែត្រការ៉េ ឱ្យទៅឈ្មោះ [redacted] យឹម គឺពិតជាដីដែលមានទីតាំងនៅភូមិខ្វា ប្រាកដមែន មិនមែនស្ថិតនៅភូមិជើងឯក ដូចការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា នោះទេ ។ បន្ទាប់ពីបានទិញដីពីឈ្មោះ [redacted] សំអឿន មកឈ្មោះ [redacted] យឹម បានកាន់កាប់ដីនោះ និងបានជួលឱ្យអ្នកដាំត្រកួននៅលើដីនោះ ដែលមានអ្នកជួលឈ្មោះ [redacted] អ៊ុច និងប្រពន្ធឈ្មោះ [redacted] ថាវី មានទីលំនៅភូមិបុរីកម្មករ សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ឈ្មោះ [redacted] វ៉ាន់ ខ្លួនមិនដែលឃើញមកទីតាំងដីនោះទេ បើទោះជាមកក៏លួចមកដែរ ។ កន្លងមកខ្លួន មិនដែលឃើញឈ្មោះ [redacted] សំអឿន និងឈ្មោះ [redacted] យឹម មានទំនាស់ ឬមានការប្រើអំពើហិង្សាអ្វីទៅឈ្មោះ [redacted] ស៊ុនប៉ា ទេ។ សព្វថ្ងៃដីនេះ ដីនេះឈ្មោះ [redacted] យឹម ជាអ្នកកាន់កាប់មិនមែនឈ្មោះ [redacted] ស៊ុនប៉ា កាន់កាប់ទេ ។ ខ្លួនមិនធ្លាប់ឃើញឈ្មោះ [redacted] ស៊ុនប៉ា មកទីតាំងដីទំនាស់ម្ដងដែរ ដោយមានទំនាស់ឡូឡាជាមួយឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឈ្មោះ [redacted] សារិន តែមិនមានការវាយតប់គ្នាទេ ដោយពេលនោះមានប្រជាជនក្នុងមូលដ្ឋានមកជួយឡូឡា ហើយភាគីខាងឈ្មោះ [redacted] ស៊ុនប៉ា ក៏ដកថយទៅវិញ ដោយមិនមានហិង្សាអ្វីទេ ។ ចំពោះរឿងដែលឈ្មោះ [redacted] ស៊ុនប៉ា ថាគាត់បានបោះបង្គោលខ្លួនមិនដឹងទេ ។ ខ្លួនមិនដឹងថាមានការវាយបង្គោលចោល ឬមានការបោះបង្គោលនៅលើដីនោះ ពីសំណាក់ភាគីណាមួយទេ ។ ចំពោះរូបថតទីតាំងដីដែលតុលាការបានបង្ហាញខ្លួននេះ ខ្លួនមិនច្បាស់ទេ ព្រោះថារូបខ្លួនមិនបានថតពីទិដ្ឋភាពរួមពីខាងក្នុងបឹងមកមាត់បឹងខាងលើ ដែលមានផ្ទះប្រជាពលរដ្ឋរស់នៅ ហេតុនេះ ខ្លួនមិនអាចចំណាំបាននៅទីតាំងណាទេ ។

-សាក្សីឈ្មោះ [redacted] **អ៊ុច** បានឆ្លើយថា ៖ ខ្លួនបានស្បថរួចហើយ ។ ខ្លួនពុំមានជាប់សាច់ញាតិអ្វីជាមួយនឹងឈ្មោះ [redacted] ស៊ុនប៉ា ,ឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឡើយ ។ ខ្លួនបានជួលដីដាំត្រកួនពីឈ្មោះ [redacted] សំអឿន តាំងពីអំឡុងដើមឆ្នាំ២០០៨ ដោយបង់ថ្លៃឈ្នួលដី ចំនួន ៣០០ (បីរយ)ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ លុះជួលបានប្រហែល ៣ ទៅ ៤ ឆ្នាំ ឈ្មោះ [redacted] សំអឿន បានផ្ទេរសិទ្ធិដីទៅឱ្យឈ្មោះ [redacted] យឹម វិញ បន្ទាប់មក ខ្លួនក៏ទៅជួលដីនោះ ដាំត្រកួនបន្តទៀត រហូតមកដល់សព្វថ្ងៃនេះ ដោយបង់ថ្លៃឈ្នួលដីទៅឱ្យឈ្មោះ [redacted] យឹម ជាប្រចាំ គឺចំនួន ៥០០ (ប្រាំរយ)ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ ដីដែលខ្លួនជួលនោះ គឺស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ខ្លួនដឹងតែរឿងប៉ុណ្ណឹងទេ ។

-សាក្សីឈ្មោះ [redacted] **សុភាព** បានឆ្លើយថា ៖ ខ្លួនបានស្បថរួចហើយ ។ ខ្លួនពុំមានជាប់សាច់ញាតិអ្វីជាមួយនឹងឈ្មោះ [redacted] ស៊ុនប៉ា ,ឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឡើយ ។ ឈ្មោះ [redacted] យឹម គឺជាអ្នកជាប់ព្រំដីជាមួយខ្ញុំបាទអស់រយៈពេលជាង ១០ឆ្នាំមកហើយ គាត់ពិតជាម្ចាស់ដីប្រាកដមែន ។ ឈ្មោះ [redacted] សុជាតិ ខ្លួនមិនដែលស្គាល់ទេ ។ ខ្លួនជាប់ព្រំតាំងពីម្ចាស់ដីដើមឈ្មោះ [redacted] សំអឿន ផ្ទេរទៅឱ្យឈ្មោះ [redacted] យឹម មិនដែល

មានម្ចាស់ឈ្មោះ [redacted] ស៊ុនប៉ា ទេ ។ កន្លងមកមិនដែលធ្វើសាក្សីឱ្យឈ្មោះ [redacted] សំអឿន ក្នុងការលក់ ដីឱ្យទៅឈ្មោះ [redacted] យីម នោះទេ ។

-សាក្សីឈ្មោះ [redacted] **សាវិន** បានឆ្លើយថា ៖ ខ្លួនមានអាយុ ៦២ឆ្នាំ ។ ខ្លួនជាអ្នកជាប់ព្រំដីជាមួយនឹងឈ្មោះ [redacted] យីម នៅក្នុងភូមិខ្វា ដោយគាត់នៅខាងត្បូង ចំណែកឯខ្លួននៅខាងជើង ។សព្វថ្ងៃនេះ គឺខ្លួនបានលក់ដីអស់បាត់ហើយ ។

-សាក្សីឈ្មោះ [redacted] **យន** បានឆ្លើយថា ៖ ខ្លួនមានអាយុ ៦២ឆ្នាំ ។ ខ្លួនជាប្រជាការពារភូមិបានដឹងរឿង និងឃើញឈ្មោះ [redacted] យីម បោះបង្គោលលើដីនោះមែន ហើយដីនោះ ជារបស់ឈ្មោះ [redacted] សំអឿន នៅក្បែរគ្នាជាមួយនឹងរូបខ្លួន ដោយខ្លួននៅខាងជើង រំលងដីរបស់ឈ្មោះ [redacted] សុភាព ១ទៀត ដីខ្លួនមាន ចំនួន ៣០អា ជាប់ប្រឡាយ ។ ឈ្មោះ [redacted] បុប្ផា ខ្លួនមិនស្គាល់ទេ ។ ឈ្មោះ [redacted]ាន់ នៅភូមិជើងឯក ។ ដីខ្លួនលក់បាត់ហើយឱ្យទៅក្រុមហ៊ុនចាក់អង្រែ មិនស្គាល់ឈ្មោះ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ុនប៉ា** នៅចំពោះមុខចៅក្រមស៊ើបសួរថា ៖ ខ្ញុំសុំបញ្ជាក់ថា ដីទំនាស់មានទំហំ ១០៤៣៧ម៉ែត្រការ៉េ ហើយដីនេះឈ្មោះ [redacted] សំអឿន បានលក់ឱ្យក្រុមឈ្មោះ [redacted] ឆេង ,ឈ្មោះ [redacted] ឆី ,ឈ្មោះ [redacted] តុក ,ឈ្មោះ [redacted] បុប្ផា ម្តងរួចហើយ កាលពីអំឡុងឆ្នាំ២០០៥។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៥ ខ្ញុំបានទិញដីទំហំ ២៥០០០ ម៉ែត្រការ៉េ ពីឈ្មោះ ឈាង ឆេង ដែលជាតំណាងឱ្យក្រុម មានឈ្មោះ [redacted] ឆេង ,ឈ្មោះ [redacted] ឆី ,ឈ្មោះ [redacted] តុក ,ឈ្មោះ [redacted] បុប្ផា ។ ដោយខ្ញុំបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ មានការបញ្ជាក់ ដោយមេភូមិជើងឯក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ និងមានការបញ្ជាក់ដោយចៅសង្កាត់លេខ ៤៥៦/០៥ បជ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ ។ ហើយខ្ញុំបានធ្វើការ ចុះវាស់វែង និងបោះបង្គោល ត្រឹមត្រូវ ។ នៅអំឡុងឆ្នាំ២០១៥ ស្រាប់តែឈ្មោះ [redacted] យីម មកបោះបង្គោលព័ទ្ធយកដីខ្ញុំ អស់ទំហំ ១០៤៣៧ ម៉ែត្រការ៉េ ។ ដោយឈ្មោះ [redacted] យីម បានអះអាងថា ដីនោះខ្លួនបានទិញពីឈ្មោះ [redacted] សំអឿន ។ ហើយថាខ្លួនមានលិខិតផ្ទេរសិទ្ធិកាន់កាប់ ប៉ុន្តែលិខិតផ្ទេរសិទ្ធិដែលឈ្មោះ [redacted] យីម ដាក់ចូលមកនៅដំណាក់កាលអយ្យការ ឃើញមានផ្តិតមេដៃភាគី និងសាក្សី តែមិនមានចុះកាលបរិច្ឆេទ និងមានការបញ្ជាក់ដោយមេភូមិ និងចៅសង្កាត់ឡើយ ។ ស្រាប់តែក្រោយមកមិនដឹងថាឈ្មោះ [redacted] យីម ទៅរត់ការ ឬមានការឃុបឃិតយ៉ាងណាទេ ស្រាប់តែមានការចុះកាលបរិច្ឆេទ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ និងមានចុះហត្ថលេខ ដោយមេភូមិខ្វា នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ។ ដីនោះជាដីតែមួយកន្លែងតែមានការដណ្តើមសមត្ថកិច្ចគ្នាគ្រប់គ្រង ។ ដីទំនាស់នោះ ឈ្មោះ [redacted] សំអឿន បានលក់ឱ្យឈ្មោះ [redacted] ឆេង ឈ្មោះ [redacted] ឆី ឈ្មោះ [redacted] តុក ឈ្មោះ [redacted] បុប្ផា រួចហើយ ដូចមានចុះក្នុងបញ្ជីសៀវភៅតម្កល់ឯកសារនៅសាលាសង្កាត់ជើងឯកលេខ ៣១៥ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ទើបខ្ញុំទិញបន្ត ស្រាប់តែនៅអំឡុងឆ្នាំ ២០១៤ នេះ ឈ្មោះ [redacted] សំអឿន មិនដឹងថាមាការឃុបឃិតជាមួយនឹងឈ្មោះ [redacted] យីម បែបណាទេ ក៏បានផ្ទេរសិទ្ធិឱ្យឈ្មោះ [redacted] យីម ម្តងទៀត ដែលមានឯកសារផ្សេងៗគ្នាដូចបានឆ្លើយបញ្ជាក់ខាងលើ ហើយលិខិតទាំងនោះម្តងគ្មានកាលបរិច្ឆេទ ម្តងមានកាលបរិច្ឆេទ ១៦.០៥.២០១២ និងមានលិខិតប្រគល់ទទួលលុយជំនួសធ្វើនៅឆ្នាំ ២០១៤ ផ្សេងទៀត ។ ចំពោះការប្រើហិង្សា ឈ្មោះ [redacted] យីម បានវាយបង្គោលរបងរបស់ខ្ញុំ និងបោះបង្គោលថ្មី ព័ទ្ធយកដីរបស់ខ្ញុំ ហើយពេលនោះខ្ញុំបោះបង្គោលថ្មីបន្ថែមទៀតឈ្មោះ [redacted] យីម និង

ឈ្មោះ [redacted] សំអឿន នាំគ្នារារាំងឡូឡា និងរករឿងខ្ញុំ ។ សូមបញ្ជាក់ថាកន្លងមកឈ្មោះ [redacted] យឹម តែងតែបង្ក ទំនាស់ និងធ្វើការរារាំងខ្ញុំក្នុងការកាន់កាប់ដី ។

ខ្ញុំសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងការធ្វើការឃុំខ្លួនជនជាប់ចោទ ទាមទារ សំណងការខូចខាត និងជំងឺចិត្ត សេវាកម្មច្បាប់ សរុបចំនួន ១០០ ០០០ (ដប់ម៉ឺន)ដុល្លារអាមេរិក ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ថាវី នៅចំពោះមុខចៅក្រមស៊ើបសួរថា ៖ នាងខ្ញុំ និងប្តីឈ្មោះ [redacted] អ៊ុច បានជួលដីដាំត្រកួន ពីឈ្មោះ [redacted] សំអឿន តាំងពីឆ្នាំអំឡុងដើមឆ្នាំ២០០៨ ដោយបង់ថ្លៃឈ្នួលដីចំនួន ៣០០ (បីរយ)ដុល្លារអាមេរិក ក្នុង ០១(មួយ)ឆ្នាំ ។លុះជួលបានប្រហែល ៣(បី) ទៅ ៤ (បួន)ឆ្នាំ ឈ្មោះ [redacted] សំអឿន បានផ្ទេរសិទ្ធិដីទៅឱ្យឈ្មោះ [redacted] យឹម វិញ បន្ទាប់មក ខ្ញុំ និងប្តី ក៏នៅជួលដីនោះដាំត្រកួនបន្តទៀត រហូតមក ដល់សព្វថ្ងៃនេះ ដោយបង់ថ្លៃឈ្នួលដីទៅឱ្យឈ្មោះ [redacted] យឹម ជាប្រចាំ គឺចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុង ០១(មួយ)ឆ្នាំ ។ ដីដែលនាងខ្ញុំ និងប្តីបានជួលនោះ គឺស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] វ៉ាន់ នៅចំពោះមុខចៅក្រមស៊ើបសួរថា ៖ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមែនជាសាច់ញាតិជាមួយឈ្មោះ [redacted] ស៊ុនប៉ា ,ឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន ឡើយ។ ខ្ញុំជាអ្នករៀបចំដីលក់ឱ្យឈ្មោះ [redacted] ស៊ុនប៉ា ។ ខ្ញុំសូមបញ្ជាក់ថា ដីទំនាស់នេះ ជាដីស្ថិតនៅភូមិជើងឯក សង្កាត់ ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ មិនមែនស្ថិតក្នុងភូមិខ្វាទេ ។ ដីនេះ ឈ្មោះ [redacted] បុប្ផា បានលក់ឱ្យ ឈ្មោះ [redacted] ស៊ុនប៉ា ហើយខ្ញុំបានទៅមើលដីនោះម្តងម្កាលដែរ ។ ចំពោះរឿងថា ឈ្មោះ [redacted] សំអឿន បានលក់ ដីនោះ ឱ្យឈ្មោះ [redacted] យឹម ខ្ញុំមិនដឹងទេ ។ ចំពោះការដែលឈ្មោះ [redacted] យឹមវាយរបងឈ្មោះ [redacted] ស៊ុនប៉ា ខ្ញុំមិនដឹង ទេ ។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដែលមានឈ្មោះ [redacted] សំអឿន លក់ដីដែលមានទីតាំងនៅភូមិខ្វា ឱ្យឈ្មោះ [redacted] យឹម នោះខ្ញុំមិនដឹងទេ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីពិនិត្យសំណុំរឿង ស្តាប់ការសួរដេញដោល ស្តាប់ចម្លើយជនជាប់ចោទ និងសាក្សី អំណានចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ជាដំបូងក្នុងនាមជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើការបញ្ជាក់ ពីអង្គហេតុជាមុនសិន កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ កូនក្តីខ្លួនឈ្មោះ [redacted] ស៊ុនប៉ា បានទិញដីពីឈ្មោះ [redacted] ឆេង មានលិខិតផ្ទេរសិទ្ធិលេខ ៤៨៦/០៥ ប.ជ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាសង្កាត់ ជើងឯក ដែលក្នុងទំហំនេះ លិខិតគល់បញ្ជីរបស់សាលាសង្កាត់ជើងឯកឈ្មោះ [redacted] សំអឿន បានផ្ទេរឱ្យក្រុម ប្រមូលទិញដីមានឈ្មោះ [redacted] ធី ,ឈ្មោះ [redacted] កុក ,ឈ្មោះ [redacted] ឆេង និងឈ្មោះ [redacted] បុប្ផា ទំហំ ១៧,៥០០ម² ផងដែរ) ។ យោងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៣១៥/០៥ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ របស់សាលាសង្កាត់ជើងឯក ឈ្មោះ [redacted] សំអឿន លក់ឱ្យឈ្មោះ [redacted] បុប្ផា ហើយកូនក្តីខ្ញុំបានទិញពីក្រុមទិញ ដីនេះ ដែលមានឈ្មោះ [redacted] ឆេង ជាតំណាង ហើយក៏បានបោះបង្គោលព្រំដី ត្រឹមត្រូវកាន់កាប់ដី និងថែរក្សា តាំងពីឆ្នាំ២០០៥ ហើយក៏បានឱ្យឈ្មោះ [redacted] វ៉ាន់ ជួយមើលដីខាងលើនេះ ជាប់ជាអចិន្ត្រៃយ៍ ។ លុះដល់អំឡុង ឆ្នាំ២០១៤ កូនក្តីខ្លួនបានលក់ដីនេះឱ្យឈ្មោះ ឃុន ទី ទំហំ ២៥៨៤១ម² ហើយពេលចុះវាស់វែង ស្រាប់តែឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] សំអឿន បានបង្កើតអង្គហេតុរឿងទិញ លក់ដីរវាងគ្នាឯង គ្មានអាជ្ញាធរដឹងឮ ដោយ

បានមកបោះបង្គោលព្រំដី រំលោភចូលដីស្របច្បាប់របស់កូនក្តីខ្លួនជាង ១ហិកតា ដោយគ្រាន់តែធ្វើលិខិតសំអាងថា បានទិញពីឈ្មោះ [redacted]សំអឿន តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីគ្មានលេខ គ្មានចុះថ្ងៃខែឆ្នាំ និងមិនមានការបញ្ជាក់ដឹងឮពីអាជ្ញាធរមូលដ្ឋានភូមិសង្កាត់ឡើយ គ្រាន់តែមានកិច្ចសន្យាសងប្រាក់ជំនួសឈ្មោះ [redacted] រ៉ាន់ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ និងមានលិខិតដដែលនេះ មួយទៀត ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ លិខិតទាំងពីរនេះ ជនត្រូវចោទបានដាក់ចូលក្នុងសំណុំរឿងខ្លួនឯង ដែលករណីនេះ ឈ្មោះ [redacted] រ៉ាន់ មិនបានដឹងឮ ឬចូលរួមផ្តិតមេដៃជាមួយទេ ។ នៅពេលកូនក្តីខ្លួន លក់ដីឱ្យឈ្មោះ [redacted] ទី តាមកិច្ចសន្យាទិញ លក់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ មិនអាចវាស់បាន ហើយដោយសំណូមពរពីភាគីឈ្មោះ [redacted] ទី វាស់វែងកាត់ដី ទំនាស់ចេញសិន កូនក្តីខ្លួនក៏យល់ព្រមវាស់វែង គិតប្រាក់ថ្លៃទិញ លក់ តែទំហំ ១២.១១៨ម² សិន ដោយមានលិខិតផ្ទេរសិទ្ធិ កាន់កាប់ដី ផ្ទះលេខ ១៩៧/០៥ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាសង្កាត់ដង្កោ (ចុះហត្ថលេខាដោយលោក [redacted] សាមឿន) ជាចៅសង្កាត់ ធ្វើលិខិតធាក់ថយថ្ងៃខែឆ្នាំ) ។ ក្នុងការប្រមូលទិញ ឈ្មោះ [redacted] ទី បានទិញដីផ្ទះម្តុំនេះរាប់សិបហិចតា ដូចមានប្លង់ឌីម៉ាស ភ្ជាប់មកជាមួយលិខិតលោក [redacted] សាមឿន ចៅសង្កាត់ចុះហត្ថលេខា ។ ការណ៍នេះមានន័យថា ដីទំនាស់ គឺនៅទីតាំងលោក [redacted] សាមឿន ទទួល ស្គាល់ និងចុះហត្ថលេខាឱ្យឈ្មោះ [redacted] ទី នេះហើយ ។ ថ្មីៗនេះក្រោយកូនក្តី ខ្ញុំស្នើសុំអន្តរាគមន៍ទៅសម្តេច នាយករដ្ឋមន្ត្រី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ក៏បានបំភ្លឺដីស្នើសុំដោះស្រាយនេះជាន់លើដី ឈ្មោះ [redacted] ទី ដែលគណៈកម្មការបានដោះស្រាយជូនលោក [redacted] ទី រួច ។ ផ្អែកទៅលើអង្គច្បាប់ កូនក្តីខ្លួនឈ្មោះ [redacted] ស៊ុនប៉ា ជាម្ចាស់កម្មសិទ្ធិលើដីនេះ ពិតប្រាកដមែន យោងតាមកិច្ចសន្យាលក់ដី និងទទួលប្រាក់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ រវាងកូនក្តីខ្ញុំ និងឈ្មោះ [redacted] ឆេង និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខ ៤៨៦/៥ បជ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ ដែលឈ្មោះ [redacted] ឆេង ផ្ទេរសិទ្ធិកាន់កាប់មកកូនក្តីខ្លួន ។ ក្រោយមកក៏បានលក់បន្តទៅឱ្យឈ្មោះ [redacted] ទី នូវទំហំ ១២,១១៨ យោងលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះ លេខ ១៩/០៥ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ របស់ចៅ សង្កាត់ដង្កោ ដែលលោក [redacted] សាមឿន ចុះហត្ថលេខានេះមានន័យ ដីរបស់កូនខ្លួនដែលកំពុងសវនាការនេះ គឺជាដីដែលមានទំនាស់ជាមួយឈ្មោះ [redacted] យឹម នេះហើយ មិនមែនដូចការបង្វែរអង្គហេតុរបស់ជនជាប់ចោទ និងសាក្សីឈ្មោះ [redacted] សាមឿន អះអាងនោះឡើយ ។ ហើយបើដីនៅទីតាំងផ្សេង ហេតុអ្វីពេលឈ្មោះ [redacted] ទី ទិញពីកូនក្តីខ្លួន ឈ្មោះ [redacted] សាមឿន អះអាងនោះឡើយ ហើយបើដីនៅទីតាំងផ្សេង ហេតុអ្វីពេលឈ្មោះ [redacted] ទី ទិញពីកូនក្តីខ្លួនឈ្មោះ [redacted] ស៊ុនប៉ា លោក [redacted] សាមឿន ជាចៅសង្កាត់ បានចុះហត្ថលេខាក្នុងសមត្ថកិច្ច ដែនដីខ្លួន រួមទាំងមានប្លង់ឌីម៉ាស់ជាង ១០ហិកតា ក៏មានឈ្មោះកូនក្តីខ្លួនឈ្មោះ [redacted] ស៊ុនប៉ា ដែរ ។ ដីទំនាស់នេះ ពិតជាដីដែលជាន់លើគ្នា ។ យោងទៅលើលិខិតលេខ ៨៥១ ដនសស.បទ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ បានបញ្ជាក់ថាដីស្នើសុំដោះស្រាយ ជាដីជាន់លើដីឈ្មោះ [redacted] ទី ដែលគណៈកម្មការបានដោះស្រាយរួច និងប្លង់បង្ហាញជទីតាំងដីនៃភូមិទា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នេះដោយសារឈ្មោះ [redacted] ទី បានយកកិច្ចសន្យាទិញពីកូនក្តីខ្លួន ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ទៅដោះស្រាយគោលនយោបាយជាមួយគណកម្មការ គឺទំហំ ២៥,៨៤១ម² ដោយឈ្មោះ [redacted] ទី

មិនបានកាត់យក តែទំហំ ១២,១១៨ម² តាមការព្រមព្រៀង និងលិខិតផ្ទេរសិទ្ធិនៅសាលា សង្កាត់ដង្កោទេ បែរជាយកទំហំដីមានក្នុងកិច្ចសន្យាទៅទូទាត់គោលនយោបាយពីគណៈកម្មការទាំងស្រុងតែម្តង ។ ឯកសារដែលភាគីឈ្មោះ [redacted] យឹម បានដាក់ជូនតុលាការមានកូនដា កិច្ចសន្យាជួលដី ដាំត្រកួន និងកញ្ឆែត ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ និងកិច្ចសន្យាជួលដីដាំត្រកួន និងកញ្ឆែត ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] យឹម និងឈ្មោះ [redacted] អ៊ុច និងប្រពន្ធឈ្មោះ [redacted] ថាវី គឺជាឯកសារសង្ស័យ ដោយទម្រង់កិច្ចសន្យា និងរចនាបទដូចគ្នាទាំងស្រុង ដោយដូរតែកាលបរិច្ឆេទចុះហត្ថលេខាតែប៉ុណ្ណោះ ហើយមិនត្រឹមត្រូវថែមទៀត ។ លើសពីនេះ លិខិតសងប្រាក់ជំនួសឈ្មោះ អ៊ុក វ៉ាន់ និងលិខិតប្រគល់ប្រាក់ថ្លៃ ដីផ្តាច់ គឺធ្វើនៅឆ្នាំ២០១៤ ត្រង់ចំណុចនេះសួរថា តើឈ្មោះ [redacted] យឹម ឯណាជួលឱ្យគេតាំងពីឆ្នាំ២០១០ ? ម្យ៉ាងទៀតលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរវាងឈ្មោះ [redacted] សំអឿន និងឈ្មោះ [redacted] យឹម ដែលម្តងដាក់ចូលតុលាការអត់មានកាលបរិច្ឆេទ និងម្តងទៀតដាក់កាលបរិច្ឆេទ គឺឆ្នាំ២០១២ ជាលិខិតធ្វើមុនការទិញលក់ និងការសងលុយជំនួសឈ្មោះ [redacted] វ៉ាន់ ដែលទើបធ្វើឆ្នាំ២០១៤ ។ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣១៥/៤ បជ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ របស់សាលាសង្កាត់ជើងឯក និងឯកសារថតចម្លងគល់បញ្ជីពី សាលាសង្កាត់ជើងឯក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ឆ្លើយពេលដេញដោលក្នុងសវនាការ ដែលថាគាត់បានប្រមូលដីអ្នកដទៃបានជាងមួយហិកតាយកមកលក់នេះ គឺស៊ីសង្វាក់គ្នា ។ ប៉ុន្តែដីនេះ គឺគាត់បានលក់រួចម្តងហើយ គឺលក់ឱ្យក្រុមរៀបដី មានឈ្មោះ [redacted] ធី , [redacted] កុក , [redacted] ឆេង និង [redacted] បុប្ផា ។ ដូចនេះ ជនជាប់ចោទឈ្មោះ [redacted] សំអឿន មិនមានដីណាទៀតសម្រាប់ទុកលក់ ឱ្យឈ្មោះ [redacted] វ៉ាន់ ឬឈ្មោះ [redacted] យឹម ទៀតទេ ។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ចំពោះការទាមទារសំណងរដ្ឋប្បវេណី បើជនជាប់ចោទទទួលស្គាល់កំហុស គឺកូនក្តីខ្លួនមិនទាមទារទេ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានពិនិត្យសំណុំរឿង ស្តាប់ការសួរដេញដោលនាពេលសវនាការ ស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសាក្សី សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្តាប់អំណានឯកសារនានាក្នុងសំណុំរឿង ឃើញថា ពិតជាមានអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងសមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ពិតប្រាកដមែន ស៊ីសង្វាក់ជាមួយនឹងភស្តុតាងនានាក្នុងសំណុំរឿង ។ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល ។ និងជនជាប់ចោទឈ្មោះ [redacted] **យឹម** ពីបទ **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យ

ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ និងផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿង ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ស្តាប់ការសួរដេញដោលនាពេលសវនាការ ស្តាប់ចម្លើយរបស់ជនជាប់ចោទ ស្តាប់ចម្លើយសាក្សី ស្តាប់អំណានឯកសារនានាក្នុងសំណុំរឿង ឃើញថា ទីតាំងដីដែលឈ្មោះ [redacted] វ៉ាន់ លក់ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី គឺមានទីតាំងស្ថិតនៅភូមិជើងឯក ចំណែកឯទីតាំងដីរបស់ជនជាប់ចោទ គឺស្ថិតនៅក្នុងភូមិខ្វា ដូចជាការបញ្ជាក់របស់សាក្សី ដែលជាចៅសង្កាត់ ក៏ដូចជាសាក្សីដែលជាអ្នកភូមិជាមួយគ្នា ដែលបានជួលដីបន្តពីឈ្មោះ [redacted] យឹម ដូច្នេះ សបញ្ជាក់ឱ្យឃើញថា ដីដែលជាកម្មវត្ថុនៃការប្តឹងផ្តល់នេះ គឺជាដីផ្សេងគ្នាពីដីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការដែលជនជាប់ចោទឈ្មោះ [redacted] សំអឿន ជាម្ចាស់ដីដើម បានលក់ឱ្យទៅឈ្មោះ [redacted] យឹម គឺឈ្មោះ [redacted] យឹម ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ដោយពុំបានបំពានទៅលើដីដែលជាកម្មសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ហេតុដូច្នេះ ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសំណូមពរសុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទបានរួចផុតពីបទចោទប្រកាន់ ។

## សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បាននិយាយសំដីចុងក្រោយបង្អស់ថា ៖ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] **យឹម** បាននិយាយសំដីចុងក្រោយបង្អស់ថា ៖ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១១៥០ "១១" ដ.ជ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងជនជាប់ចោទ

ឈ្មោះ [redacted]យីម ពីបទ **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

២-មាត្រានៃច្បាប់ភូមិបាល ៖

-មាត្រា ២៥៣ បានចែងថា ៖ "ជនណាដែលប្រើអំពើហិង្សាទៅអ្នកកាន់កាប់អលចនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន)រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬ/និងដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ២(ពីរ)ឆ្នាំ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស" ។

-មាត្រា ២៥៥ បានចែងថា ៖ "ជនណាដែលបានលួចលក់ ឬលួចបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ៣(បី)ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន" ។

៣-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សំអឿន និងឈ្មោះ[redacted] យីម ថា "មិនដែលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ុនប៉ា នេះទេ ហើយដីរបស់ខ្លួន នៅស្ថិតនៅទីតាំងភូមិខ្វា សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលដំបូងខ្លួនបានលក់ឱ្យទៅឈ្មោះ អ៊ុក វ៉ាន់ តែមិនបានទូទាត់ប្រាក់ឱ្យគ្រប់ចំនួន និងឈ្មោះ[redacted]វ៉ាន់ បានកាត់កងឱ្យទៅឈ្មោះ [redacted]យីម បន្តចេញលុយជំនួស ដោយឈ្មោះ [redacted]យីម បានបង់ប្រាក់បន្ថែមមកខ្លួន ហើយបានលក់ឱ្យទៅឈ្មោះ [redacted] យីម ដោយមានអាជ្ញាធរដឹងឮ" ។

៤-ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted]សាមឿន បានបញ្ជាក់ថា ខ្លួនធ្លាប់ធ្វើជាចៅសង្កាត់ដង្កោ នៅអំឡុងខែកញ្ញា ឆ្នាំ១៩៩១ និងបាន ឈប់ពីមុខងារនេះ នៅឆ្នាំ២០១៧ នៅពេលមានការប្រកាសសុពលភាពចៅសង្កាត់ថ្មី ។ ដីទំនាស់ដែលមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ហើយមានចុះហត្ថលេខារបស់មេភូមិ ប៊ិច ប៊ុន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដែលមានឈ្មោះ [redacted]សំអឿន ផ្ទេរសិទ្ធិដី ដែលមានទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ មានទំហំ ១០.០០០ម៉ែត្រការ៉េ ឱ្យទៅឈ្មោះ [redacted] យីម គឺពិតជាដីដែលមានទីតាំងនៅភូមិខ្វា ប្រាកដមែន មិនមែនស្ថិតនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ ដូចការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ុនប៉ា នោះទេ ។ ខ្លួនសុំបញ្ជាក់ពីប្រវត្តិដីនេះថា ដើមឡើយឈ្មោះ តាំង យីម មានការប្តឹងផ្តល់ជាមួយឈ្មោះ[redacted] វ៉ាន់ ក្រោយមកមានការព្រមព្រៀងគ្នាដោយឈ្មោះ[redacted]វ៉ាន់ យល់ព្រមសងដីឱ្យ ឈ្មោះ [redacted]យីម ដែលមានទីតាំងនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ហើយឈ្មោះ [redacted]វ៉ាន់ និងឈ្មោះ [redacted] យីម បានមកសាលាសង្កាត់ដង្កោស្នើសុំធ្វើលិខិតផ្ទេរសិទ្ធិដី ភូមិខ្វា ឱ្យទៅឈ្មោះ [redacted] យីម ខ្លួនក៏បានចាត់មន្ត្រីសង្កាត់មួយរូប គឺលោក [redacted] ទីម ជាសមាជិកក្រុមប្រឹក្សាសង្កាត់ទទួលបន្ទុកទំនាស់ដីធ្លី និងមេភូមិខ្វា លោក [redacted] ប៊ុន ដើម្បីចុះទៅពិនិត្យទីតាំង និងធ្វើការកំណត់ព្រំ ដើម្បីធ្វើលិខិតផ្ទេរសិទ្ធ ។ ក្រោយមកឈ្មោះ [redacted]សំអឿន ចេញមកអះអាងថាដីនោះ ជា



Scanned with CamScanner

ដីរបស់គាត់ដែលបានលក់ឱ្យឈ្មោះ [redacted] វ៉ាន់ តែឈ្មោះ [redacted] វ៉ាន់ បានព្រមព្រៀងគ្នាដោយឈ្មោះ [redacted] យឹម ព្រមព្រៀងចេញលុយជំនួសឈ្មោះ [redacted] វ៉ាន់ បង្គ្រប់ថ្លៃដីឱ្យទៅឈ្មោះ [redacted] សំអឿន ។ ហើយឈ្មោះ [redacted] សំអឿន បានព្រមព្រៀងផ្តិតមេដៃទទួលប្រាក់ និងផ្ទេរសិទ្ធិដីទំនាស់ដែលមានទីតាំងនៅភូមិខ្វា ឱ្យទៅឈ្មោះ [redacted] យឹម តែម្តង ។ សូមបញ្ជាក់ថា ដីនេះ ឈ្មោះ [redacted] សំអឿន ជាម្ចាស់ដីដែលបានកាន់កាប់បន្តពីដូនតា មក និងធ្វើស្រែប្រាំងនៅពេលរដូវទឹកស្រកជាប្រចាំ ហើយគាត់ក៏ជាអ្នកស្រុកភូមិនៅទីនោះ ។ នៅពេលដែលឈ្មោះ [redacted] វ៉ាន់ ចុះទៅចង្អុលដី គឺដីនោះពិតជាមាន ទីតាំងនៅភូមិខ្វាប្រាកដមែន ។ មុនពេលរឿងទំនាស់នេះកើតឡើង ខ្លួនមិនដែលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា នេះទេ ។

៥-ផ្អែកតាមចម្លើយសាក្សីឈ្មោះ [redacted] អ៊ិច ,ឈ្មោះ [redacted] ថាវី ,ឈ្មោះ [redacted] ប៊ុន ,ឈ្មោ [redacted] សាវិន ,ឈ្មោះ [redacted] យន ដែលបានឆ្លើយប្រហាក់ប្រហែលគ្នា គឺជាដីរបស់ឈ្មោះ [redacted] សំអឿន កាន់កាប់តាំងពីដូនតាមក ដែលមានទីតាំងស្ថិតនៅភូមិខ្វា ពុំមែនស្ថិតនៅភូមិជើងឯកនោះទេ ហើយឈ្មោះ [redacted] សំអឿន ពិតជាបានលក់ឱ្យទៅឈ្មោះ [redacted] យឹម ពិតប្រាកដមែន ។

៧-តាមចម្លើយសាក្សីឈ្មោះ [redacted] វ៉ាន់ បានឆ្លើយថា ឈ្មោះ [redacted] បុប្ផា បានលក់ដីឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុនប៉ា មានទីតាំងនៅភូមិជើងឯក មិនមែនទីតាំងនៅភូមិខ្វា នោះទេ ។

៨-**ដោយហេតុថា** មិនមានភស្តុតាងបញ្ជាក់ថា ឈ្មោះ [redacted] ស៊ុនប៉ា ជាកម្មសិទ្ធិករ ឬជាអ្នកកាន់កាប់លើដីទាំងនេះឡើយ ហេតុនេះ ឃើញថា អំពើរបស់ជនជាប់ចោទមិនប្រើហិង្សា ឬលួចលក់អចលនវត្ថុឡើយ ។

៩-**ដោយហេតុថា** មិនឃើញមានការបញ្ជាក់ សិទ្ធិស្ថាពរភាពថាជនជាប់ចោទបានបំពានកម្មសិទ្ធិឯកជនឡើយ ហេតុនេះ មិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ តាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ,តាមមាត្រា ២៥៣ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

១០-**ដោយហេតុថា** មានសាក្សី និងភស្តុតាងដោះបន្ទុក ឃើញថា ការចោទប្តឹង ស្ថិតក្នុងភាពសង្ស័យ គប្បីយល់ឃើញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពុំមែនជាបទល្មើស **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល ហើយអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **យឹម** ក៏ពុំមែនជាបទល្មើស **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

១១-ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពីបទ **លួចលក់អចលន-វត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល ។ និងជនជាប់ចោទឈ្មោះ [redacted] **យឹម** ពីបទ **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ



Scanned with CamScanner

២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងមាត្រា **២៩** នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល ។

១២-គប្បីសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សំអឿន និងឈ្មោះ [redacted] យឹម រួចផុតពីបទចោទប្រកាន់បាន តាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

**១-ក.**ឱ្យឈ្មោះ [redacted] **សំអឿន** រួចផុតពីបទចោទប្រកាន់ពីបទ **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល ។

**ខ.**ឱ្យឈ្មោះ [redacted] **យឹម** រួចផុតពីបទចោទប្រកាន់ពីបទ **សមគំនិតក្នុងអំពើលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៥៥** នៃច្បាប់ភូមិបាល និងមាត្រា **២៩** នៃក្រមព្រហ្មទណ្ឌ និងបទ **ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ,នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំអឿន** និងឈ្មោះ [redacted] **យឹម** ចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក [redacted] **ហេង** និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ ចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក [redacted] **ហេង** បើកផ្លូវបណ្តឹងឧបាស្រ័យតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា ៖** [redacted] | **ហត្ថលេខា និងត្រា ៖** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ , ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]